ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

.............

ក្រសួងមហាផ្ទៃ

លេខ: ៥៦៧ ប.ក

ភ្នំពេញ. ថ្ងៃទី ២១ ខែ ១១ ឆ្នាំ ១៩៩៧

# ប្រកាស

## ស្តីពី

## សៀវភៅស្នាក់នៅ

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម ន.ស.រ.ក.ម ០១៩៦ .០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦
- បានឃើញ អនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧៣ អ.ន.ក្រ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីសៀវភៅស្នាក់នៅ
- តាមសំណូមពរចាំបាច់របស់ ព្រះរាជាណាចក្រ កម្ពុជា

## សំរេច

ប្រការ ១ : សៀវភៅស្នាក់នៅ មានគោលដៅ ចុះឈ្មោះ និង គ្រប់គ្រងមនុស្សដែលកំពុងរស់នៅ លើទឹកដី នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ជនគ្រប់រូបមានកាតព្វកិច្ចចុះឈ្មោះ ក្នុងសៀវភៅស្នាក់នៅ តាមទីកន្លែងដែលខ្លួនស្នាក់នៅជាប់លាប់ ក្នុងក្រុមគ្រួសារមួយជាកំណត់ ។

ប្រការ ៣ : ជនម្នាក់ៗ ឬ ក្រុមគ្រួសារនីមួយៗ មិនអនុញ្ញាតអោយចុះឈ្មោះ ក្នុងសៀវភៅស្នាក់នៅពីរកន្លែង បានឡើយ ទោះមានផ្ទះច្រើនខ្នង ឬ ច្រើនល្វែងក៏ដោយ ។

ប្រការ៤ : ក្រុមគ្រួសារ រួមមានបណ្ដាមនុស្ស ដែលពាក់ពន្ធ័ខាងសេដ្ឋកិច្ច ក្នុងការហូបចុក ហើយស្នាក់នៅផ្ទះតែមួយ ។

- ក្រុមសមូហភាពរួមមាន បណ្ដាមនុស្សរស់នៅតាម មជ្ឈមណ្ឌលនានា ដោយមានការចាត់តាំង ហើយមានទំនាក់ទំនងខាងសេដ្ឋកិច្ច និង ការងារ អ្នកទាំងនោះត្រូវចុះឈ្មោះក្នុងបញ្ជីគ្រប់គ្រងដោយឡែក ។

ប្រការ៥ : អាចចាត់ទុកជាអ្នកទទួលខុសត្រូវចម្បង ( មេគ្រួសារ ) គឺជនដែលមានអាយុពី ១៨ ឆ្នាំឡើង ហើយមានសមត្ថភាពគ្រប់គ្រង សមាជិកក្រុមគ្រួសារ ដែលរស់នៅជាមួយខ្លួនចំពោះមុខច្បាប់ ។

ប្រការ៦ : ជនមិនបានត្រូវចុះឈ្មោះ ក្នុងសៀវភៅស្នាក់គឺ :

- ជនបរទេស មិនមែន អន្តោប្រវេសន៍

- កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និង នគរបាលជាតិ ដែលរស់នៅប្រមូលផ្ដុំក្នុងបន្ទាយ មិនមែនជាគេហដ្ឋាន ។ អ្នកទាំងនោះអាចចុះឈ្មោះជាមួយក្រុមគ្រួសាររៀងៗខ្លួនបាន ។

ប្រការ៧ : ជនគ្រប់រូបអាចសុំផ្លាស់ប្ដូរ ទីលំនៅ កែតម្រូវផ្សេងៗ ក្នុងសៀវភៅស្នាក់នៅបាន ។ ករណីមានការប្ដឹង ប្រកាន់ ក្នុងប្រការអ្វីណាមួយតាមផ្លូវច្បាប់ សមត្ថកិច្ចនគរបាលមូលដ្ឋានអាចផ្អាកជាបណ្ដោះអាសន្ន ។

ប្រការ៨ : មេក្រុមគ្រួសារនីមួយៗ ត្រូវជូនដំណឹងទៅសមត្ថកិច្ចនគរបាលមូលដ្ឋាន របស់ខ្លួនអំពី :

- ការកើត ការស្លាប់ ការចាកចេញ ឬ ចំណូលថ្មី ឬ ការបាត់ខ្លួនរបស់សមាជិកណាម្នាក់ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។

- ការជូនដំណឹងនេះ យ៉ាងយូរ រយៈពេល ៣ ថ្ងៃ ។

ប្រការ៩ : រាល់ការចុះឈ្មោះស្នាក់នៅ ការគ្រប់គ្រង ការប្រែប្រួល ការផ្លាស់ប្ដូរ និងរាល់ការ កែតម្រូវផ្សេងៗ ជាសមត្ថកិច្ចរបស់នគរបាលរដ្ឋបាល ។

ប្រការ១០ : សៀវភៅស្នាក់នៅ ត្រូវបង្ហាញនៅពេលមានការត្រួតពិនិត្យពី នគរបាលមានសមត្ថកិច្ច សៀវភៅស្នាក់នៅនេះ អាចដកហូតពីក្រុមគ្រួសារ ឬ សាម៉ីជនណា មិនគោរពតាមបទបញ្ញត្តិនៃច្បាប់ ។

- ដូចជាធ្វើការកោសលប់ ការសរសេរត្រួត សរសេរក្លែងក្លាយ ឬ ចុះឈ្មោះក្លែងក្លាយ ។

- ការឈប់ទទួលស្គាល់សៀវភៅស្នាក់នៅរបស់ក្រុមគ្រួសារ ឬ ជនណាមួយត្រូវសំរេចដោយសមត្ថកិច្ច នគរបាលថ្នាក់លើ ៤៤ ។

ប្រការ១១ : ជនណាដែលពុំព្រមចុះឈ្មោះខ្លួន និង សមាជិកក្រុមគ្រួសារខ្លួន ក្នុងសៀវភៅស្នាក់នៅរយៈពេលយ៉ាងយូរបីខែ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តតាមមាត្រា ៦ នៃអនុក្រិត្យស្តីពីសៀវភៅស្នាក់នៅ ។

ប្រការ១២ : អគ្គនាយកដ្ឋាននគរបាលជាតិ ត្រូវកំណត់ពីបែបបទ នៃការចុះបញ្ជីគ្រប់គ្រង តាមតំរូវឯកសាររបស់ក្រសួង ។

ប្រការ១៣ : ជនណាដែល អនុវត្តផ្ទុយពីប្រការ នៃប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

ប្រការ១៤ : ប្រការទាំងឡាយណា ដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥ : នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល អគ្គនាយកនៃអគ្គនាយកដ្ឋាន នគរបាលជាតិ អភិបាលខេត្ត-ក្រុង និងគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ទ ប្ត ល ផ្ញ ទ* :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ " ដើម្បីជ្រាប "
- ឯកសារ - កាលប្បវត្តិ